ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

លេខៈ ៧៧ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារសម្រាប់ជួយពិនិត្យ និងកែសម្រួលលើសេចក្តីព្រាង ឯកសារពិគ្រោះប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- យោងចំណារដឹកនាំខ្ពស់របស់សម្តេចនាយករដ្ឋមន្ត្រីចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០០៦

## សម្រេច

**ប្រការ ១ :** ត្រូវបានបង្កើតក្រុមការងារសម្រាប់ជួយពិនិត្យ និងកែសម្រួលលើសេចក្តីព្រាង ឯកសារពិគ្រោះប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ដែលមានសមាសភាព ដូចខាងក្រោម :

| | | |
|---|---|---|
| ១-ឯកឧត្តម **អ៊ឹម សិទ្ធី** | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | ប្រធាន |
| ២-ឯកឧត្តម **ស៊ិន សំណាង** | ប្រធានរាជបណ្ឌិតសភាកម្ពុជា | អនុប្រធាន |
| ៣-ឯកឧត្តម **សំ ចន្ទ្រាបុត្រ** | អនុប្រធានរាជបណ្ឌិតសភាកម្ពុជា | អនុប្រធាន |
| ៤-ឯកឧត្តម **ឆយ អូន** | សមាជិកក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | សមាជិកប្រចាំការ |
| ៥-ឯកឧត្តម **អ៊ិត សុខ** | សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ | សមាជិក |
| ៦-លោកស្រី **ឆន់ សារ៉ឹម** | ប្រធាននាយកដ្ឋានស្រាវជ្រាវគរុកោសល្យ នៃក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| | វិត្តិសាស្ត្រ និងវិទ្យាសាស្ត្រនយោបាយ កម្ពុជា | សមាជិក |

**ប្រការ ២ :** ក្រុមការងារនេះមានភារកិច្ច :

-ពិនិត្យ និងកែសម្រួលលើសេចក្តីព្រាង ឯកសារពិគ្រោះប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ដើម្បីបញ្ចូលអត្ថបទនេះក្នុងកម្មវិធីសិក្សានៅមធ្យមសិក្សា និងឧត្តមសិក្សា របស់ក្រសួងអប់រំ យុវជន និងកីឡា

-ធ្វើរបាយការណ៍អំពីលទ្ធផលនៃការពិនិត្យ និងកែសម្រួលលើអត្ថបទនេះ ជូនឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។

**ប្រការ ៣ :** ប្រធានរាជបណ្ឌិតសភាកម្ពុជា ប្រធានក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រធាននាយកដ្ឋានរដ្ឋបាល នាយកដ្ឋាន និងអង្គភាពចំណុះទីស្តីការគណៈរដ្ឋមន្ត្រី និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ 10 ឆ្នាំ ២០០៦

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**សុខ អាន**

**កន្លែងទទួល :**

-ក្រសួងអប់រំ យុវជន និងកីឡា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី

-ដូចប្រការ ៣

-ឯកសារ កាលប្បវត្តិ

decision 02-10-06